**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៣៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រង និងការត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៨ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស -រកម-០១៩៦-០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ-គត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំងក្រសួងការពារជាតិ

-បានឃើញក្រឹត្យលេខ១១ក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា

-បានឃើញច្បាប់ព្រហ្មទណ្ឌអន្តរកាល

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១** អនុក្រឹត្យនេះមានគោលដៅបង្ការ និងបង្រ្កាបដើម្បីគ្រប់គ្រង និងត្រួតពិនិត្យ ការកាន់កាប់ ការស្តុក ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា ២** ចាត់ទុកជាអាវុធ ជាតិផ្ទុះ រួមមាន ៖

១-កាំភ្លើងវែង កាំភ្លើងខ្លីគ្រប់ប្រភេទ ។

២-កាំភ្លើងប្រភេទឧស្ម័នហៀរទឹកភ្នែក ឬ សន្លប់ ឬ ឧស្ម័នពុល ។

៣-កាំភ្លើងស្វ័យប្រវត្តិ ពាក់កណ្តាលស្វ័យប្រវត្តិគ្រប់ប្រភេទ ។
៤-កាំភ្លើងខ្ទប់សម្លេង ឬ ឧបករណ៍ខ្ទប់សម្លេង ។
៥-រ៉ុកកែតគ្រប់ប្រភេទ ។
៦-អាវុធគីមី គ្រប់ប្រភេទ ។
៧-អាវុធជីវសាស្ត្រគ្រប់ប្រភេទ ។
៨-ដំបងឆក់គ្រប់ប្រភេទ ។
៩-គ្រាប់បែក គ្រាប់មីនគ្រប់ប្រភេទ ។
១០-ជាតិផ្ទុះ ឬ សារធាតុផ្ទុះគ្រប់ប្រភេទ ។
១១-គ្រាប់កាំភ្លើងគ្រប់ប្រភេទ ។

**មាត្រា ៣** អាវុធជាតិផ្ទុះគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធឯកជនបានឡើយ ។

ជនណាដែលសព្វថ្ងៃនេះ មានអាវុធជាតិផ្ទុះ ទោះជាទុកនៅទីកន្លែងណាក៏ដោយត្រូវយកអាវុធជាតិផ្ទុះនោះមកប្រគល់អោយអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ។

**មាត្រា ៤** ហាមដាច់ខាត ការលក់ ការទិញដូរ ការធ្វើអំណោយ ការស្តុកទុកក្នុងផ្ទះ ឬ ទីកន្លែងណាផ្សេងទៀតនូវអាវុធ ជាតិផ្ទុះដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៥** ការនាំចូល ការផលិតអាវុធជាតិផ្ទុះគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ៖
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធជាតិផ្ទុះនោះបម្រើអោយវិស័យការពារជាតិ ។
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធជាតិផ្ទុះនោះបម្រើអោយវិស័យសន្តិសុខជាតិ ។
ការដឹកជញ្ជូនអាវុធជាតិផ្ទុះគ្រប់ប្រភេទនៅផ្ទៃក្នុងប្រទេស ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ បើអាវុធជាតិផ្ទុះនោះបម្រើអោយវិស័យសន្តិសុខជាតិ ឬ ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ បើអាវុធជាតិផ្ទុះនោះបម្រើអោយវិស័យ ការពារជាតិ ។

## ជំពូកទី ២
## ការគ្រប់គ្រង និង ការត្រួតពិនិត្យ ការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ

**មាត្រា ៦** ក្រសួងការពារជាតិមានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រង និងការត្រួតពិនិត្យការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទក្នុងកងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ រួមទាំងអាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលបានរក្សាទុកក្នុងឃ្លាំង ។

**មាត្រា ៧** ក្រសួងមហាផ្ទៃមានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រង និងការត្រួតពិនិត្យ ការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទក្នុងកងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងជីវពល និងកងសន្តិសុខធនាគារជាតិនៃកម្ពុជា រួមទាំងអាវុធជាតិផ្ទុះគ្រប់ប្រភេទដែលបានរក្សាទុកក្នុងឃ្លាំង ។

**មាត្រា ៨** ការនាំចូល ការប្រើប្រាស់ ការដឹកជញ្ជូន ការស្តុកទុកក្នុងឃ្លាំងនូវជាតិផ្ទុះ ឬសារធាតុផ្ទុះគ្រប់ប្រភេទសម្រាប់បម្រើអោយ ការផលិត ឬ សេវាកម្មសាធារណៈត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

នីតិវិធី និងបែបបទនៃការសុំលិខិតអនុញ្ញាតនេះត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣
## អំពីសមត្ថកិច្ចក្នុងការចេញលិខិត
## អនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ

**មាត្រា ៩** ក្រសួងការពារជាតិ មានសិទ្ធិផ្តល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទចំពោះកងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ។

**មាត្រា ១០** ក្រសួងមហាផ្ទៃមានសិទ្ធិផ្តល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទចំពោះកងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងជីវពល និងកងសន្តិសុខធនាគារជាតិនៃកម្ពុជា ។

**មាត្រា ១១** នីតិវិធី និងលក្ខខ័ណ្ឌ នៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះសម្រាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងជីវពល និងកងសន្តិសុខធនាគារជាតិ នៃកម្ពុជា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

## ជំពូកទី ៤
## សិទ្ធិប្រើប្រាស់កាំភ្លើងខ្លីជាលក្ខណៈផ្ទាល់ខ្លួន

**មាត្រា ១២** មន្ត្រីរាជការស្ថាប័នស៊ីវិល ដែលអាចអនុញ្ញាតអោយប្រើប្រាស់កាំភ្លើងខ្លីយកតាមខ្លួនមួយនាក់មួយដើមជាលក្ខណៈផ្ទាល់ខ្លួនបានតាមការកំណត់ថ្នាក់ដូចខាងក្រោម ៖

-នៅស្ថាប័ននីតិបញ្ញត្តិ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងសមាជិក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

-នៅសាលាជម្រះក្តី គឺប្រធាន និងអគ្គព្រះរាជអាជ្ញាតុលាការកំពូល ។

-នៅក្រសួងស្ថាប័ន ចាប់ពីថ្នាក់អគ្គនាយកឡើងទៅ ។

-នៅខេត្ត-ក្រុង រាជធានីភ្នំពេញ ចាប់ពីអភិបាលរងខេត្ត-ក្រុងឡើងទៅ ។

-នៅស្រុក ខណ្ឌ គឺ អភិបាលស្រុក ខណ្ឌ ។

**មាត្រា ១៣** កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងកម្លាំងនគរបាលជាតិ អាចអនុញ្ញាតអោយប្រើប្រាស់កាំភ្លើងខ្លីយកតាមខ្លួនមួយនាក់មួយដើមជាលក្ខណៈផ្ទាល់ខ្លួនបានចាប់ពីថ្នាក់វរសេនីយ៍ឯកឡើងទៅ។

**មាត្រា ១៤** ចំពោះកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងកម្លាំងនគរបាលជាតិ ក្រៅពីការកំណត់ក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ អាចប្រើប្រាស់អាវុធ ជាតិផ្ទុះបានតែក្នុងពេលប្រតិបត្តិការ ។
ក្នុងពេលប្រតិបត្តិការនេះ ត្រូវមានភ្ជាប់ជាមួយលិខិតបញ្ជាបេសកកម្ម និងមានលិខិតអនុញ្ញាតប្រើប្រាស់អាវុធជាតិផ្ទុះជាលក្ខណៈសមូហភាព ។

ចំពោះលិខិតបញ្ជាបេសកកម្ម នៃកងយោធពលខេមរភូមិន្ទត្រូវចុះហត្ថលេខាដោយខុទ្ទកាល័យក្រសួងការពារជាតិ ឬ ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ឬ មេបញ្ជាការ ជើងគោកមេបញ្ជាការ ជើងទឹក ឬ មេបញ្ជាការជើងអាកាស ឬ មេបញ្ជាការកងរាជអាវុធហត្ថ ឬ មេបញ្ជាការយោធភូមិភាគ ឬ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ។

សមត្ថកិច្ចចុះហត្ថលេខាលើលិខិតបញ្ជាបេសកកម្មនៃកងយោធពលខេមរភូមិន្ទ ដែលពុំមានចែងខាងលើត្រូវកំណត់ដោយអគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ។

ចំពោះលិខិតបញ្ជាបេសកកម្មនៃកងកម្លាំងនគរបាលជាតិ កងសន្តិសុខធនាគារជាតិនៃកម្ពុជា ត្រូវចុះហត្ថលេខាដោយអគ្គនាយកនគរបាលជាតិ ស្នងការនគរបាលខេត្ត-ក្រុង ។

ក្រោយពេលចប់កិច្ចប្រតិបត្តិការភ្លាមត្រូវយកអាវុធជាតិផ្ទុះ រួមទាំងលិខិតប្រើប្រាស់អាវុធជាតិផ្ទុះនោះមករក្សាទុកនៅតាមអង្គភាពសាមី ។

កម្រិតនៃកិច្ចប្រតិបត្តិការដែលចាំបាច់ត្រូវប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសអន្តរ ក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

**មាត្រា ១៥** ជនបរទេសគ្មានសិទ្ធិប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ។

**មាត្រា ១៦** កាំភ្លើងវែង មិនអនុញ្ញាតអោយប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួនឡើយ ។

**មាត្រា ១៧** ហាមយកអាវុធជាតិផ្ទុះគ្រប់ប្រភេទ ចូលក្នុងរាជធានីភ្នំពេញ លើកលែងតែមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិ ។

បែបបទ និងលក្ខខ័ណ្ឌ នៃការសុំអនុញ្ញាតយកអាវុធជាតិផ្ទុះគ្រប់ប្រភេទ ចូលរាជធានីភ្នំពេញនិងចំនួន ឬ ស្តីទទួលផ្ញើអាវុធជាតិផ្ទុះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ។

## ជំពូកទី ៥

## ទោសប្បញ្ញត្តិ

**មាត្រា ១៨** ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ស្តីពីការផ្តន្ទាទោសការកាន់អាវុធនិងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា និងច្បាប់ព្រហ្មទណ្ឌអន្តរកាលចំពោះជនណាដែលបានប្រព្រឹត្តល្មើសនឹងចំណុចណាមួយខាងក្រោមនេះ ៖

១-ជនណាប្រព្រឹត្តល្មើសនឹងមាត្រា៣ មាត្រា៤ មាត្រា៨ មាត្រា១២ មាត្រា១៣ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃអនុក្រឹត្យនេះ ។

២-ជនណាដែលនាំចូល លក់ ទិញដូរ កាន់កាប់ រក្សាទុក យកអាវុធជាតិផ្ទុះ ឬ គ្រាប់រំសេវតាមខ្លួនដោយគ្មានលិខិតអនុញ្ញាត ។

៣-ជនណាដែលបានផ្តល់អោយ បានអោយខ្ចី ឬ បានជួលអាវុធជាតិផ្ទុះ គ្រាប់រំសេវ ដែលខ្លួនមានទៅជនដទៃ ។

៤-ជនណាបានដកកាំភ្លើងភ្ជង់អ្នកដទៃ ឬ បាញ់គំរាមកំហែងអ្នកដទៃ ឬ បាញ់ខ្យល់ ភ្លៀង ព្យុះ ឬ បាញ់លេង ឬ ការបាញ់សាកក្រៅពីកន្លែងបាញ់សាកដែលកំណត់ដោយក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិ ។

**មាត្រា ១៩** ជនណាមានលិខិតអនុញ្ញាតយកអាវុធតាមខ្លួនហើយធ្វើអោយបាត់គ្រាប់កាំភ្លើង ឬ មានចំនួនគ្រាប់កាំភ្លើង លើសពីការអនុញ្ញាតអោយប្រើប្រាស់ដោយគ្មានមូលហេតុត្រឹមត្រូវ ជននោះត្រូវដកហូតអាវុធ និងលិខិតអនុញ្ញាតនោះមកវិញ ។

ចំនួនគ្រាប់កាំភ្លើងដែលអនុញ្ញាតអោយប្រើប្រាស់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ។

**មាត្រា ២០** វត្ថុតាងនៃបទល្មើសដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ និងត្រូវបញ្ជូនឲ្យទៅអគ្គនាយកដ្ឋាននគរបាលជាតិ ដើម្បីគ្រប់គ្រង លើកលែងតែអាវុធធុនធ្ងន់ដែលជាសម្ភារៈសឹកត្រូវបញ្ជូនទៅអគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ ដើម្បីគ្រប់គ្រង ។

**មាត្រា ២១** ត្រូវដកហូតអាវុធ និងលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ ព្រមទាំងមិនអោយប្រើប្រាស់អាវុធជាស្ថាពរជនណាដែលបានយកអាវុធ ជាតិផ្ទុះទៅបង្កបទល្មើស ។

**មាត្រា ២២** អាជ្ញាធរមានសមត្ថកិច្ចណា ចេញលិខិតអោយប្រើប្រាស់អាវុធខុសពីការកំណត់ដូចមានចែងក្នុង មាត្រា១២ មាត្រា ១៣ និង មាត្រា១៤ នៃអនុក្រឹត្យនេះត្រូវផ្តន្ទាទោសតាមច្បាប់ ជាធរមាន ។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា ២៣** ក្រោយអនុក្រឹត្យនេះចូលជាធរមាន ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ត្រូវពិភាក្សាពីការផ្ទេរ កងជីវពល ពីក្រសួងការពារជាតិ មកក្រសួងមហាផ្ទៃ ។

**មាត្រា ២៤** ជនដែលមានសិទ្ធិប្រើប្រាស់កាំភ្លើងខ្លីជាលក្ខណៈផ្ទាល់ខ្លួន តាមការកំណត់ដូចមានចែងក្នុងមាត្រា ១៦ និង មាត្រា ១៣ នៃអនុក្រឹត្យនេះត្រូវមកសុំលិខិតអនុញ្ញាតប្រើប្រាស់អាវុធពីក្រសួងមហាផ្ទៃ ចំពោះ នគរបាលជាតិ និងមន្ត្រីរាជការស៊ីវិល ឬ ក្រសួងការពារជាតិ ចំពោះកងយោធពលខេមរភូមិន្ទ និងកងរាជ អាវុធហត្ថក្នុងរយៈពេលយ៉ាងយូរ ពីរខែក្រោយអនុក្រឹត្យនេះចូលជាធរមាន ។

ក្នុងករណីមិនអនុវត្តត្រឹមត្រូវតាមការកំណត់ខាងលើនេះសាមីជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ នឹង ត្រូវរឹបអូសអាវុធនោះទុកជាសម្បត្តិរដ្ឋ ។

**មាត្រា ២៥** ក្រោយអនុក្រឹត្យនេះចូលជាធរមានបង្កើតក្លឹបបាញ់ស៊ីប ក្លឹបបាញ់កំសាន្តបែបកីឡាទាំងអស់ត្រូវបិទ

ចំពោះអាវុធជាតិផ្ទុះគ្រប់ប្រភេទដែលប្រើប្រាស់ក្នុងក្លឹបទាំងអស់ ត្រូវយកប្រគល់ឲ្យអគ្គនាយកដ្ឋាន នគរបាលជាតិ ដើម្បីរក្សាទុកជាសម្បត្តិរដ្ឋ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ២៦** អនុក្រឹត្យលេខ៦២ អនក្រ-បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយ នឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៧** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារ ជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធ និងអភិបាលខេត្ត ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមករា ឆ្នាំ ១៩៩៩

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ខេង យូ ហុកគី ទៀ បាញ់ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យ ព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២៧
ឯកសារ-កាលប្បវត្តិ